**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង ផែនការ**

គណៈកម្មាធិការ លទ្ធកម្ម(គល.PC)

លេខ.១៣៧៩......ផក/គល

## សេចក្តីជូនដំណឹង

## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃការងារសាងសង់អគារមន្ទីរផែនការខេត្តស្វាយរៀង

ក្រសួងផែនការ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនក្នុងស្រុក ( គិតទាំងសហគ្រាសឯកត្តបុគ្គល) និង ក្រុមហ៊ុនក្រៅប្រទេសទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា ក្រសួងផែនការនឹងដាក់ឱ្យដេញថ្លៃប្រកួតប្រជែងក្នុងស្រុក ដើម្បីជ្រើសរើស "អ្នកទទួលការ" សាងសង់អគារមន្ទីរផែនការខេត្តស្វាយរៀង ។

ក្រសួងផែនការ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុនបំពេញដើម្បីចូលរួមដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្មនៃក្រសួងផែនការ អាសយដ្ឋានក្រសួងផែនការ ផ្លូវលេខ៣៦០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី...២៨......ខែ..វិច្ឆិកា...... ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ ។

ឯកសារដេញថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មនៃក្រសួងផែនការយ៉ាងយូរបំផុតត្រឹមថ្ងៃទី...២៨......ខែ...ធ្នូ............ឆ្នាំ២០១៨ វេលាម៉ោង..១៥:០០.នាទី..។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅ នៅអង្គភាពលទ្ធកម្មនៃក្រសួងផែនការ តាមអាសយដ្ឋានខាងលើ វេលាម៉ោង១៥:០០នាទី...ថ្ងៃទី...២៨......ខែ...ធ្នូ.............ឆ្នាំ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់ឯកសារដេញថ្លៃបានតែមួយគត់ ។

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មនៃក្រសួងផែនការ ដើម្បីទិញឯកសារដេញថ្លៃនិងសាកសួរពត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ភ្នំពេញ ថ្ងៃទី...២៧...ខែ...វិច្ឆិកា......ឆ្នាំ២០១៨

ប្រធានគណៈកម្មាធិការលទ្ធកម្ម(គល.PC)

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងផែនការ

**ឆាយ ថន**

សូមទាក់ទង

ទូរស័ព្ទលេខ ៖ (០២៣)២១២៣៦០

ចម្លងជូន

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  ( អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ )
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ-កាលប្បវត្តិ